## ▶ មានអ្នកណាខ្លះដែលអ្នកអាចទាក់ទងបាន

**អនុព័ន្ធការងារអមស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ**
លេខទូរស័ព្ទ៖
+៦៦(0) ៩៨ ០៩២ ៥៩០៥
+៦៦(0) ៩៨ ៨១៦ ៥៥១៨
+៦៦(0) ០២ ៩៥៧ ៥៨៥១-២

**លេខទូរស័ព្ទនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម**
ទូរស័ព្ទ៖ ០៩៧ ៩២០ ២០២៣
**មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**ខេត្តកណ្តាល**
ទូរស័ព្ទ៖ ០១២ ៦៨៧ ៨៥៣
**ខេត្តតាកែវ**
ទូរស័ព្ទ៖ ០៨៥ ៨២៨ ២៦៣
**ខេត្តព្រះសីហនុ**
ទូរស័ព្ទ៖ ០១៧ ៣៨០ ០៣៥
**ខេត្តកំពង់ស្ពឺ**
ទូរស័ព្ទ៖ ០៩២ ៦២៨ ២១២

**ខេត្តក្រចេះ**
ទូរស័ព្ទ៖ ០៨៨ ៧២២ ១៦ ៦៦
**ខេត្តប៉ៃលិន**
ទូរស័ព្ទ៖ ០៩៦ ៩០៩ ៨៧ ៧៩
**ខេត្តស្ទឹងត្រែង**
ទូរស័ព្ទ៖ ០១២ ៨៤៣ ៦៦៦
**ខេត្តកោះកុង**
ទូរស័ព្ទ៖ ០៧១ ៧៩១ ៩២ ៩៣
**ខេត្តកំពង់ចាម**
ទូរស័ព្ទ៖ ០៩២ ២២៥ ៣២៣២
**ខេត្តកំពត**
ទូរស័ព្ទ៖ ០៣១ ៣៨៨ ៨៨ ១១
**ខេត្តស្វាយរៀង**
ទូរស័ព្ទ៖ ០៧១ ៩០០ ៨៩៩៨
**ខេត្តបន្ទាយមានជ័យ**
ទូរស័ព្ទ៖ ០៧៦ ៧២៦ ២៦២៦
**ខេត្តសៀមរាប**
ទូរស័ព្ទ៖ ០១៧ ២៥៩ ៣៥៩
**ខេត្តបាត់ដំបង**
ទូរស័ព្ទ៖ ០១២ ៧២៧ ០៦៨
**ខេត្តកែប**
ទូរស័ព្ទ៖ ០១២ ៣៣៦ ៧៧៨

**ខេត្តត្បូងឃ្មុំ**
ទូរស័ព្ទ៖ ០៨៧ ៩៨៩ ៩០៧
**ខេត្តកំពង់ធំ**
ទូរស័ព្ទ៖ ០១៧ ៨ ២៦៣ ២៦៤
**ខេត្តព្រៃវែង**
ទូរស័ព្ទ៖ ០៨៩ ៦៨៩ ៩៣៣
**ខេត្តព្រះវិហារ**
ទូរស័ព្ទ៖ ០១២ ៨៦៧ ៨៥៥
**ខេត្តមណ្ឌលគិរី**
ទូរស័ព្ទ៖ ០៩៧ ៩៧៦ ៦២៨២
**ខេត្តពោធិ៍សាត់**
ទូរស័ព្ទ៖ ០៩២ ៦៨៨ ២៧៥
**ខេត្តរតនគិរី**
ទូរស័ព្ទ៖ ០៩៨ ៨៨៨ ៦៨៨
**ខេត្តឧត្តរមានជ័យ**
ទូរស័ព្ទ៖ ០១២ ៦០១ ១៣១

**មជ្ឈមណ្ឌលធនធានពលករទេសន្តរប្រវេសន៍**
**ខេត្តបន្ទាយមានជ័យ**
ទូរស័ព្ទ៖ (+៨៥៥) ៩៣ ៥៥៦ ៦១៩
(+៨៥៥) ៩៣ ៥៥៦ ៦១៨

**ខេត្តសៀមរាប**
ទូរស័ព្ទ៖ (+៨៥៥) ៦៣ ២១០ ២៧៧
(+៨៥៥) ៧៨ ៦៨២ ២៦៨
**ខេត្តបាត់ដំបង**
ទូរស័ព្ទ៖ (+៨៥៥) ៩៧ ៣៦៩ ៧៧៧៩
**ខេត្តព្រៃវែង**
ទូរស័ព្ទ៖ (+៨៥៥) ១២ ៨៣៦ ៥៣៦
(+៨៥៥) ៨៣ ២១០ ២៧៧
**ខេត្តពោធិ៍សាត់**
ទូរស័ព្ទ៖ (+៨៥៥) ៥២ ៧៨០ ២៧៧
(+៨៥៥) ១០ ៧០៦ ៦៥៥
**ខេត្តកំពង់ធំ**
ទូរស័ព្ទ៖ (+៨៥៥) ៧៧ ៨៥០ ៨៨៨
(+៨៥៥) ៦២ ២១០ ២៧៧
**ខេត្តកោះកុង**
ទូរស័ព្ទ៖ (+៨៥៥) ៨៨ ៩៣១ ៣២៨២
**ខេត្តកំពង់ចាម**
ទូរស័ព្ទ៖ (+៨៥៥) ១២ ៨៨០ ៨០៨
(+៨៥៥) ១៧ ៩៩៨ ៨១៨
**ខេត្តកំពត**
ទូរស័ព្ទ៖ (+៨៥៥) ៩២ ៩១៩ ១០៧
(+៨៥៥) ១៦ ៥០៦ ៦៥៥

**ក្រសួងការងារប្រទេសថៃ**
ទូរស័ព្ទ៖ ១៥០៦/១៥៨៦/១៣០០
**មជ្ឈមណ្ឌលប្រឹក្សាយោបល់ពលករទេសន្តរប្រវេសន៍ការិយាល័យការងារ**
**ខេត្តសៈមុតសាខន**
ជាន់ទី៣ លេខ៣២-៣៣ ផ្លូវឯកកាឆៃ
ឃុំមហាឆៃ ស្រុក/ខេត្តសៈមុតសាខន
ទូរស័ព្ទ៖ ០៣៨ ៨៣៦២២៣-២៥
០៦១-៨០៧៨៧៦៦
**ខេត្តសៈមុតប្រាកាន**
លេខ១៧៦ ផ្លូវលេខ៨ អាគារA ជាន់ទី២
ឃុំតាឡាត់ធីបនីម បាងភ្លីយៃ
ស្រុកបាងភ្លី
ទូរស័ព្ទ៖ ០២ ៣៩៥៥៩៩២
**ខេត្តរ៉ះណង**
លេខ៥៥/៨ ផ្លូវលេខ៣ ឃុំបានគ្រីន
ស្រុក/ខេត្តរ៉ះណង
ទូរស័ព្ទ៖ ០៧៧-៨៦២០២៦-៨
**ខេត្តស៊ូរ៉ាតថានី**
ផ្លូវស៊ូរ៉ាតណៈសាន ឃុំថាក់លែ
ស្រុក/ខេត្តស៊ូរ៉ាតថានី
ទូរស័ព្ទ៖ ០៧៧ ៣៥៥៤២៦
**ខេត្តស៊ុងខ្លា**
អាគារសំផាកនចាស់ ជាន់ទី២
ក្រុងស៊ុងខ្លា ផ្លូវរ៉ាតឆាដាំណឹន
ឃុំប៊ីយ៉ាង ស្រុក/ខេត្តស៊ុងខ្លា
ទូរស័ព្ទ៖ ០៧៨ ៣១៨៨៨៥
០៩៣ ០០២១៦៧១

**ខេត្តតាក**
សាខាម៉ែសុត លេខ១៨៩ ផ្លូវលេខ២
ថាសៃវុធខាំផែងមឿង ម៉ែសុត
៦៣១១០
ទូរស័ព្ទ៖ ០៥៥-៥៦៣៦៣៩
០៩៦-៦៦៩៦២៨៨
**ខេត្តឈុនប៊ុរី**
១៩៩ ផ្លូវលេខ៣ ឃុំសាម៉េត
ស្រុក/ខេត្តឈុនប៊ុរី
ទូរស័ព្ទ៖ ០៣៨-៣៩៨០៥៣
**ខេត្តណៈខនរ៉ាតស៊ីម៉ា**
៣៦៨ ផ្លូវសឿបស៊ីរី ឃុំ/ស្រុក/ខេត្ត
ណៈខនរ៉ាតស៊ីម៉ា
ទូរស័ព្ទ៖ ០៨៤-៣៥៥២៦៥-៧
**មជ្ឈមណ្ឌលធនធានពលករទេសន្តរប្រវេសន៍រ៉ាក់ថៃ - ខេត្តសៈមុតប្រាកាន**
៨០/៨០៣ ផ្លូវលេខ៨៥ ធីបផារ៉ាន់១
ស្រុកយ៉ាយថេប ផាឡាក់
ស្រុក/ខេត្តសៈមុតប្រាកាន
ទូរស័ព្ទ៖ ០២៣៨០១១២៣
**មូលនិធិរ៉ាក់ថៃ - ក្រុងបាងកក**
១៨៥ ផ្លូវ ប្រាឌីផាត់៦ ផាយ៉ាថៃ
ក្រុងបាងកក
ទូរស័ព្ទ៖ ០២២៦៥៦៨៨៨
**គ្លីនិកច្បាប់ការងារ/មូលនិធិសម្រាប់អភិវឌ្ឍ និងគ្រប់គ្រងសិទ្ធិមនុស្ស - ម៉ែសុត**
១៣៨/៣១ ផ្លូវអិនថាគីរី ស្រុកម៉ែសុត
ខេត្តតាក-63110
ទូរស័ព្ទ៖ ០៥៥៥៣៥៩៩៨/
០៨៩២៧៣៨៧១១
**ការិយាល័យមូលនិធិសិទ្ធិមនុស្ស និងអភិវឌ្ឍ - ក្រុងបាងកក**
១០៩ ផ្លូវសិទ្ធិឆុន វិថីសុធិសានវីនីសៃ
សំសៀននុក ហួយក្វាង ក្រុងបាងកក
១០៣១០
ទូរស័ព្ទ៖ ០២២៧៧៦៨៨២

**សហជីពពាណិជ្ជ កម្មថៃ-ខេត្តសៈមុតប្រាកាន ៩២០/៣៩៣-៩ ធីបផារ៉ាន់១ វិថីធីផាឡាក់**
**ខេត្តសៈមុតប្រាកាន**
ទូរស័ព្ទ៖ ០២៣៨៤០៨៣៨
០៨៣០២០៦៩៧២
**ការិយាល័យមូលនិធិលើកកម្ពស់ពលករនិងការងារ - ក្រុងបាងកក**
៦៧៧/៦ រ៉ាតផ្លូវ ៥/១ ឈុំផន ឆាឈុចាក
ក្រុងបាងកក ១០៩០០
ទូរស័ព្ទ៖ ០២៥១៣៩២៨២
០៨៥៣២៧២៩៧១
**មូលនិធិ MAP - ខេត្តឈៀងម៉ៃ**
៦៣/៣០ ៣០ អ៊ូម៉ុង ផ្លូវលេខ៨ ម៉ូ៨
ស្រុកស៊ុថេប ខេត្តឈៀងម៉ៃ ៥០២០០
ទូរស័ព្ទ៖ ០៥៣៨១១២០២
០៨៦៩២១៩១៣៩ (ថៃយៃ)
០៨៦៣៦៩០៧៦២ (ថៃ)

**មូលនិធិឈៀងរ៉ៃ MWG (មូលនិធិសានយីប)**
៣៥១០ ផ្លូវឌីនខែង ស្រុកឌីនខែង
ក្រុងបាងកក
E: manager@mwgthailand.org

**បណ្តាញសិទ្ធិពលករ**
**ខេត្តស៊ុងខ្លា**
២៧ សៃងាំ ផ្លូវ៤ស្ទួនម៉ាក ឃុំប៊ូយ៉ាង
ខេត្តស៊ុងខ្លា ៩០០០០
ទូរស័ព្ទ៖ ០៧៨៣១៨២៦២
**ខេត្តឈុំផន**
៣៨៥/១៦ ផ្លូវ២ប៉ាកណាម ស្រុក/
ខេត្តឈុំផន ៨៦១២០
**ខេត្តរ៉ះណង**
៧៣/២៥ ផ្លូវលេខ៥ បាងរីង ស្រុក/
ខេត្តរ៉ះណង ៨៥០០០
ទូរស័ព្ទ៖ ០៧៧៨១០២១៧
**ខេត្តត្រាត**
៣០៥/២ ផ្លូវលេខ៥ ហាតឡេក ខ្លងយៃ
ខេត្តត្រាត ២៣១១០
ទូរស័ព្ទ៖ ០៣៩៥១៣៥០០

SHIP TO SHORE RIGHTS | SOUTH EAST ASIA

International Labour Organization

Funded by the European Union

# តើអ្នកកំពុងគិតដល់ការធ្វើទេសន្តរប្រវេសន៍ក្នុងផ្នែកនេសាទ និងកែច្នៃអាហារសមុទ្រមែនទេ?



## ព័ត៌មាននេះនឹងជួយអ្នកក្នុងការធ្វើទេសន្តរប្រវេសន៍ការងារទៅបរទេស ប្រកបដោយសុវត្ថិភាព និងទទួលបានការងារសមរម្យ

ការធ្វើទេសន្តរប្រវេសន៍ការងារអាចផ្តល់ឱ្យអ្នកនូវអត្ថប្រយោជន៍ផ្សេងៗ
អនុវត្តតាមគន្លឹះទាំងនេះ ដើម្បីធ្វើទេសន្តរប្រវេសន៍ដោយសុវត្ថិភាព និងទទួលបានអត្ថប្រយោជន៍ពីការងារនៅបរទេស

# តើធ្វើដូចម្តេចទើបទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពីការធ្វើទេសន្តរប្រវេសន៍?



## ០១ ត្រូវមានព័ត៌មាន

ប្រមូលព័ត៌មានឱ្យបានច្រើនតាមដែលអ្នកអាចធ្វើបានមុនពេលសម្រេចចិត្តធ្វើទេសន្តរប្រវេសន៍ការងារដូចជា ការចំណាយ តម្រូវការឯកសារ អំពីការរស់នៅនិងលក្ខខណ្ឌការងារនៅបរទេស បញ្ហាប្រឈមដែលអ្នកអាចជួបប្រទះ របៀបដើម្បីទទួលបានការជួយ និងរបៀបផ្ញើប្រាក់ទៅផ្ទះ។




## ០២ ឯកសារសម្រាប់ទេសន្តរប្រវេសន៍ការងារ

ការធ្វើទេសន្តរប្រវេសន៍ការងារអាចមានហានិភ័យមួយចំនួន ប៉ុន្តែប្រសិនបើអ្នកធ្វើទេសន្តរប្រវេសន៍ការងារដោយមានលិខិតឆ្លងដែនដែលមានសុពលភាព ទិដ្ឋាការការងារ និងបណ្ណអនុញ្ញាតការងារត្រឹមត្រូវ អ្នកអាចជៀសផុតពីការចាប់ខ្លួន ឬនិរទេសចេញពីប្រទេសគោលដៅ ។



## ០៣ សើុបសួរអំពីទីភ្នាក់ងារជ្រើសរើសពលករ និងអ្នករត់ការរបស់អ្នក

សើុបសួរអំពីទីភ្នាក់ងារជ្រើសរើស ឬអ្នករត់ការដើម្បីឱ្យប្រាកដថាពួកគេមានអាជ្ញាប័ណ្ណត្រឹមត្រូវ និងមានកេរ្តិ៍ឈ្មោះល្អពីទេសន្តរប្រវេសករផ្សេងទៀតដែលបានប្រើប្រាស់សេវាកម្មរបស់ពួកគេ។




## ០៤ ត្រូវចុះហត្ថលេខាលើកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរមុនពេលអ្នកទៅធ្វើការនៅបរទេស

អ្នកត្រូវចុះហត្ថលេខាលើកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរជាមួយទីភ្នាក់ងារជ្រើសរើសពលករ ឬនិយោជករបស់អ្នកមុនពេលអ្នកចេញទៅធ្វើការនៅបរទេស។ ត្រូវប្រាកដថាអ្នកបានអាន និងយល់លក្ខខណ្ឌទាំងអស់នៅក្នុងកិច្ចសន្យាមុនពេលអ្នកចុះហត្ថលេខា។




## ០៥ ត្រូវរក្សាឯកសារជាមួយអ្នក និងថតចម្លងទុក

ត្រូវរក្សាឯកសារជាមួយអ្នក និងថតចម្លងលិខិតឆ្លងដែន ទិដ្ឋាការការងារ បណ្ណអនុញ្ញាតការងារ កិច្ចសន្យា ការងារ អត្តសញ្ញាណបណ្ណ និងឯកសារពាក់ព័ន្ធផ្សេងៗដែលចាំបាច់ បង្ការក្នុងករណីបាត់បង់។



## ០៦ ត្រៀមខ្លួនសម្រាប់ករណីមានអាសន្ន

មុនពេលអ្នកធ្វើដំណើរទៅធ្វើការនៅបរទេសត្រូវផ្តល់ព័ត៌មានអំពីការទៅធ្វើការនៅបរទេសទៅដល់មិត្តភ័ក្តិ និងក្រុមគ្រួសារសម្រាប់ទាក់ទង ហើយត្រូវប្រាកដថាអ្នកមានលុយគ្រប់គ្រាន់នៅជាប់ខ្លួនសម្រាប់ធ្វើដំណើរត្រឡប់មកប្រទេសកំណើតវិញក្នុងករណីមានអាសន្ន។



## ០៧ រក្សាទំនាក់ទំនងជាប្រចាំជាមួយមិត្តភក្តិ និងក្រុមគ្រួសារ

ទាក់ទងជាប្រចាំជាមួយមិត្តភក្តិ និងក្រុមគ្រួសាររបស់អ្នកនៅប្រទេសកំណើតដើម្បីឱ្យពួកគេដឹងថាអ្នកមានសុវត្ថិភាព និងបង្កើតបណ្តាញមិត្តភក្តិដែលជឿទុកចិត្តនៅក្នុងប្រទេសគោលដៅ។



## ០៨ ប្រសិនអ្នកជួបបញ្ហានៅកន្លែងការងារ

ប្រសិនបើអ្នកមានវិវាទការងារនៅកន្លែងធ្វើការ អ្នកគួរតែស្វែងរកព័ត៌មាន និងជំនួយពីនរណាម្នាក់ដែលអ្នកទុកចិត្ត។ ប្រសិនបើអ្នកមានការពិបាកក្នុងការពិភាក្សាដោយផ្ទាល់ជាមួយទីភ្នាក់ងារជ្រើសរើសឯកជន ឬនិយោជករបស់អ្នក អ្នកអាចទាក់ទងទៅអនុព័ន្ធការងារ/ស្ថានទូត អាជ្ញាធរមានសមត្ថកិច្ចនៅប្រទេសគោលដៅ អង្គការក្រៅរដ្ឋាភិបាល និងសហជីពដើម្បីសុំជំនួយ។

# សិទ្ធិការងាររបស់ពលករទេសន្តរប្រវេសន៍ផ្នែកនេសាទ និងកែច្នៃអាហារសមុទ្រនៅក្នុងប្រទេសថៃ



## ០១ អ្នកមានសិទ្ធិទទួលបានប្រាក់ឈ្នួលអប្បបរមាតាមច្បាប់កំណត់

ពលករផ្នែកនេសាទ និងកែច្នៃអាហារសមុទ្រត្រូវតែទទួលបានប្រាក់ឈ្នួលអប្បបរមាចន្លោះពី ៣២៨-៣៥៤ បាតក្នុងមួយថ្ងៃ ដែលត្រូវបានអនុវត្តចាប់ពី ខែតុលា ឆ្នាំ២០២២។



## ០២ អ្នកមានសិទ្ធិទទួលបានពេលវេលាសម្រាក និងបើមានការងារបន្ថែមម៉ោងណាមួយគឺពុត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត

ផ្នែកកែច្នៃអាហារសមុទ្រ៖ម៉ោងធ្វើការធម្មតាគឺ ៨ម៉ោងក្នុងមួយថ្ងៃ ៦ថ្ងៃក្នុងមួយសប្តាហ៍(៤៨ម៉ោង)។ ពលករត្រូវទទួលបានរយៈពេលសម្រាកយ៉ាងតិច១ម៉ោងបន្ទាប់ពីធ្វើការបានរយៈពេល ៥ម៉ោង។
ផ្នែកនេសាទ៖ ការសម្រាក១០ម៉ោងត្រូវតែផ្តល់ឱ្យក្នុងរយៈពេល២៤ម៉ោង (សម្រាកយ៉ាងហោចណាស់៧៧ម៉ោងក្នុងមួយសប្តាហ៍)។



## ០៣ ពលករផ្នែកកែច្នៃអាហារសមុទ្រមានសិទ្ធិទទួលបានប្រាក់ឈ្នួលបន្ថែមម៉ោង

ផ្នែកកែច្នៃអាហារសមុទ្រ៖ ប្រាក់ឈ្នួលបន្ថែមម៉ោងគឺស្មើនឹង១.៥ដងនៃអត្រាប្រាក់ឈ្នួលធម្មតា បន្ទាប់ពីបំពេញការងារបាន៨ម៉ោងក្នុងមួយថ្ងៃឬ៤៨ម៉ោងក្នុងមួយសប្តាហ៍។ ប្រាក់បន្ថែមម៉ោងគឺស្មើនឹង៣ដងនៃអត្រាប្រាក់ឈ្នួលធម្មតាសម្រាប់ការងារបន្ថែមម៉ោងនៅថ្ងៃឈប់សម្រាក។
ផ្នែកនេសាទ៖ ពលករមិនត្រូវបានអនុញ្ញាតឱ្យធ្វើការបន្ថែមទេពីព្រោះកាលវិភាគការងារមិនទៀងទាត់ ។



## ០៤ អ្នកមានសិទ្ធិទទួលបានឧបករណ៍ការពារខ្លួន និងការបណ្តុះបណ្តាលស្តីពីសុវត្ថិភាព និងសុខភាពដោយឥតគិតថ្លៃ

ពលករផ្នែកនេសាទ និងកែច្នៃអាហារសមុទ្រ ត្រូវទទួលបាន ឧបករណ៍សុវត្ថិភាពការងារពីនិយោជកដោយមិនគិតថ្លៃ និងការបណ្តុះបណ្តាលចាំបាច់ណាមួយស្តីពីសុខភាព និងសុវត្ថិភាពការងារ។



## ០៥ អ្នកមានសិទ្ធិឈប់សម្រាកពេលឈឺ

ពលករផ្នែកនេសាទ និងកែច្នៃអាហារសមុទ្រ មានសិទ្ធិឈប់សម្រាកពេលមានជំងឺរហូតដល់៣០ថ្ងៃនៃថ្ងៃធ្វើការក្នុងមួយឆ្នាំ។



## ០៦ អ្នកមានសិទ្ធិឈប់សម្រាកមាតុភាព

ពលករផ្នែកនេសាទនិងកែច្នៃអាហារសមុទ្រមានសិទ្ធិឈប់សម្រាកសម្រាលកូនចំនួន៩៨ថ្ងៃ ដែលរួមបញ្ចូលការឈប់សម្រាកចំនួន៤៥ថ្ងៃដោយទទួលបានប្រាក់ឈ្នួល។



## ០៧ អ្នកមានសិទ្ធិឈប់សម្រាកប្រចាំឆ្នាំ

ផ្នែកកែច្នៃអាហារសមុទ្រ៖ បន្ទាប់ពីធ្វើការបានរយៈពេលមួយឆ្នាំ អ្នកត្រូវទទួលបានការអនុញ្ញាតឱ្យឈប់សម្រាកប្រចាំឆ្នាំចំនួន៦ថ្ងៃ។ អ្នកមានសិទ្ធិឈប់សម្រាកបុណ្យជាតិចំនួន១៣ថ្ងៃក្នុងមួយឆ្នាំដោយទទួលបានប្រាក់ឈ្នួល ។
ផ្នែកនេសាទ៖ អ្នកត្រូវបានអនុញ្ញាតឱ្យឈប់សម្រាកប្រចាំឆ្នាំចំនួន៣០ថ្ងៃជំនួសឱ្យការមិនទទួលបានការឈប់សម្រាកប្រចាំសប្តាហ៍ និងថ្ងៃឈប់សម្រាកបុណ្យប្រពៃណី។



## ០៨ អ្នកមានសិទ្ធិចូលរួមសហជីព ឬសមាគម

ពលករផ្នែកនេសាទ និងកែច្នៃអាហារសមុទ្រមានសិទ្ធិចូលរួមជាសមាជិកសហជីពនៅកន្លែងធ្វើការ ឬជាសមាជិកសមាគម។ និយោជកមិនអាចហាមឃាត់ពលករក្នុងការចូលរួមជាសមាជិកសហជីព ឬសមាគមឡើយ។